# ពិនិត្យមើលទឹកអនាម័យលាងដៃរបស់អ្នក

## ចូរកុំប្រើផលិតផលនៅក្នុង បញ្ជីរាយឈ្មោះរបស់ FDA

នៅថ្ងៃទី 8/14/20 FDA បានផ្តល់ដំបូន្មានដល់អ្នកប្រើប្រាស់កុំឲ្យប្រើផលិតផលចំនួន 157 ដែលផលិតដោយក្រុមហ៊ុនចំនួន 46។ សូមត្រួតពិនិត្យមើលបញ្ជីរាយឈ្មោះរបស់ FDA សម្រាប់ព័ត៌មានចុងក្រោយបំផុតដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាញឹកញាប់។

**បញ្ជីរាយឈ្មោះរួមបញ្ចូលផលិតផលដែលអាចនឹង៖**

- មានសារជាតុមេថាណុល (អាកុលឈើ) ឬ 1-ប្រូប៉ាណុល(1-propanol) ដែលអាចបណ្តាលឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរដូចជាពិការភ្នែក ខូចសរសៃប្រសាទ និងរហូតអាចដល់ស្លាប់។
- មានឆ្លងមេរោគ។
- មិនមានជាតិអាកុលគ្រប់គ្រាន់ដើម្បីមានប្រសិទ្ធភាពល្អ។

## ការណែនាំអំពីទឹកអនាម័យលាងដៃ

- ចូរកុំលេបទឹកអនាម័យលាងដៃ
- ដាក់ទឹកអនាម័យលាងដៃឲ្យផុតពីដៃក្មេងនិងត្រួតពិនិត្យមើលការប្រើរបស់ពួកគេ។
- ចៀសវាងផលិតផលដែលដាក់ថា “FDA-approved” [អនុញ្ញាតិដោយ FDA] នៅលើស្លាកផលិតផល គ្មានទឹកអនាម័យលាងដៃណាដែលត្រូវបានអនុញ្ញាតិដោយ FDA ទេ។
- ស្វែងរកការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រជាបន្ទាន់ប្រសិនបើអ្នកបានលេបទឹកអនាម័យលាងដៃ ឬកំពុងមានរោគសញ្ញាលើស្បែករបស់អ្នកបន្ទាប់ពីប្រើផលិតផលទាំងនេះម្តងហើយម្តងទៀត។ រោគសញ្ញារួមមានឈឺក្បាល ស្រវាំងភ្នែកឬងងឹតភ្នែក ក្អួតចង្អោរ ក្អួត ឈឺពោះ ច្របូកច្របល់ បាត់បង់ការដឹងទិសដៅ មិនស្វរវាស់វៃ ជីពចរដើយឺតនិងដកដង្ហើមយឺត រលាកស្បែកឬរលាកភ្នែក។
- ទាក់ទងទៅមណ្ឌលទាក់ទងនឹងការពុលរបស់អ្នកនៅ 1-800-222-1222 សម្រាប់ដំបូន្មាន។



បញ្ជីរាយឈ្មោះផលិតផលរបស់ FDA ដែលត្រូវចៀសវៀង អាចរកបាននៅ៖
www.fda.gov/drugs/drug-safety-and-availability/fda-updates-hand-sanitizers-consumers-should-not-use